# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

**ព្រះរាជក្រម នស/រកម/០៩៩៩/១០**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/១២ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី ការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី១៣ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី១៧ ខែ សីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី១ និងដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមរដ្ឋធម្មនុញ្ញ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ ១៩៩៩ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ ៖

# ច្បាប់

## ស្តីពី

## ការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

**មាត្រា១ .-**

ត្រូវបានបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ .-**

ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារី និង អតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ .-**

ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចអមដោយរដ្ឋលេខាធិការ និង / ឬ អនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

**មាត្រា៤ .-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៥ .-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦ .-**

ច្បាប់នេះ ត្រូវប្រកាសជាប្រញាប់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រម នស/រកម/០៩៩៩/១១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣